# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

# សេចក្តីប្រកាសព័ត៌មាន

កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បណ្តាញពហុវិស័យបានចេញនូវសេចក្តីថ្លែងការរួមរបស់ខ្លួនដោយស្នើឱ្យរាជរដ្ឋាភិបាល ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លុបចោលសេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្ម ហើយវិទ្យុអាស៊ីសេរីក៏បានផ្សាយថា ក្រុមតំណាងកសិករចំនួន ១៥ខេត្ត ស្នើឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទម្លាក់ចោលសេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្ម។

ករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកត់សម្គាល់ឃើញថា៖ សេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្ម ដែលក្រុមបណ្តាញពហុវិស័យក៏ដូចជាវិទ្យុអាស៊ីសេរីយកមកពិភាក្សានិងផ្សាយនេះ គឺផ្អែកលើសេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្មចាស់ដែលមាន១៣ជំពូក និង១១៤មាត្រា ជាសេចក្តីព្រាងដំណាក់កាលទី៣ តាំងពីខែមីនា ឆ្នាំ២០១៦ និងគ្មានតម្លៃសម្រាប់ធ្វើការពិភាក្សា។ បច្ចុប្បន្នសេចក្តីព្រាងច្បាប់នេះត្រូវបានធ្វើការកែលម្អជាបន្តបន្ទាប់ តាមរយៈសិក្ខាសាលាថ្នាក់តំបន់ចំនួន០៣លើករហូតសម្រេចបាននូវសេចក្តីព្រាងចុងក្រោយលើកទី៦ ដែលមាន១៣ ជំពូក និង១២១មាត្រា ខណៈដែលសេចក្តីព្រាងនេះបានដាក់បញ្ចូលនូវធាតុចូលល្អៗទាំងឡាយពីបណ្តាអ្នកពាក់ព័ន្ធរួមទាំង មន្ទីរ អង្គការសង្គមស៊ីវិល វិស័យឯកជន តំណាងកសិករ និងតំណាងបងប្អូនជនជាតិដើមភាគតិចពីគ្រប់បណ្តារាជធានី-ខេត្តទាំងអស់ក្នុងគោលបំណងកែសម្រួលឱ្យស្របតាមទម្រង់អន្តរជាតិ និងខ្លឹមសារគ្របដណ្តប់លើទិដ្ឋភាពគតិយុត្ត ទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពគ្រប់គ្រងដោយចៀសវាងការដាក់សម្ពាធលើកសិករដែលប្រើប្រាស់ដីកសិកម្ម និងភាពស្មុគស្មាញក្នុងការអនុវត្តន៍ច្បាប់ ព្រមទាំងធានាសង្គតិភាពជាមួយច្បាប់ភូមិបាល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ហើយក្រសួងក៏ពុំទាន់បានប្រជុំសម្រេច និងអនុម័តជារួមនៅឡើយទេ។

ចំពោះមុខនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងអញ្ជើញ ក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន ព្រមទាំងតំណាងកសិករ និងជនជាតិដើមភាគតិច ចូលរួមពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់លើកទី៦នេះ នៅក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដែលគ្រោងរៀបចំឡើងនៅរាជធានីភ្នំពេញនាចុងខែធ្នូ ឆ្នាំ២០១៦ខាងមុខនេះ ដើម្បីប្រមូលនូវធាតុចូលសំខាន់ៗថ្មីទៀតសម្រាប់ធ្វើការកែសម្រួលឱ្យកាន់តែប្រសើរឡើង ជាប្រយោជន៍ដល់ការគ្រប់គ្រង់ធនធានដីកសិកម្ម ក៏ដូចជាធនធានធម្មជាតិទាំងមូលឱ្យមាននិរន្តរភាព។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសង្ឃឹមយ៉ាងមុតមាំថាបណ្តាញពហុវិស័យ ក៏ដូចជាវិទ្យុអាស៊ីសេរីធ្វើការសហការជាមួយអគ្គនាយកដ្ឋានកសិកម្មឱ្យបានល្អប្រសើរ ដើម្បីជាប្រយោជន៍ដល់ប្រជាកសិករក៏ដូចជាចូលរួមដល់ការគ្រប់គ្រង និងការពារធនធានធម្មជាតិរបស់កម្ពុជាយើង។

រាជធានីភ្នំពេញ,ថ្ងៃទី..០៦..ខែ..ធ្នូ..ឆ្នាំ២០១៦

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**